# សាកលវិទ្យាល័យ Sheffield

## មហាវិទ្យាល័យនីតិសាស្ត្រ

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jun-2016, 13:41
CMS/CFO: Sann Rada

ឈ្មោះ៖ សាស្ត្រាចារ្យ Nicholas Tsagourias

អាសយដ្ឋាន៖

Bartolomé
Winter Street
Sheffield
S3 7ND

កាលបរិច្ឆេទ៖ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦

ទូរសព្ទ៖ + ៤៤(0) ១១៤ ២២២ ៦៨០៥

ទូរលេខ៖ + ៤៤(0) ១១៤ ២២២ ៦៨៣២

អ៊ីមែល៖ Nicholas.Tsagourias@sheffield.ac.uk

## អ្នកមិនមែនជាភាគីផ្ញើជូនសហចៅក្រមស៊ើបអង្កេតអន្តរជាតិ

*តាមច្បាប់ទម្លាប់អន្តរជាតិដែលចូលជាធរមាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ តើការវាយប្រហាររបស់រដ្ឋ ឬ អង្គការមកលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនឯង អាច ឬក៏មិនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល បើយោងតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។*

### ជំនាញរបស់អ្នកមិនមែនជាភាគី

អ្នកមិនមែនជាភាគីនៃសារណានេះឈ្មោះ Nicholas Tsagourias ជាសាស្ត្រាចារ្យជំនាញច្បាប់អន្តរជាតិនៅសាកលវិទ្យាល័យសេហ្វហ្វីល ចក្រភពអង់គ្លេស ហើយបច្ចុប្បន្ននេះជាសហការីនៅមជ្ឈមណ្ឌល Stockon សម្រាប់ការសិក្សាច្បាប់អន្តរជាតិ សាកលវិទ្យាល័យ US Naval War College។ ខ្ញុំគឺជាអ្នកជំនាញច្បាប់ស្តីពីជម្លោះប្រដាប់អាវុធ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដោយបានធ្វើការស្រាវជ្រាវ និងបោះពុម្ពផ្សាយឯកសារជាច្រើននៅក្នុងវិស័យទាំងនេះ។

## មាតិកា


| | |
|---|---|
| លក្ខណៈ និងនិយមន័យអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | កថាខណ្ឌ ១-១១ |
| និយមន័យអំពីជនស៊ីវិលនៅក្នុងជម្លោះប្រដាប់អាវុធ | កថាខណ្ឌ ១២-១៧ |
| បុគ្គលិកយោធាជាជនស៊ីវិលនៅក្នុងអំឡុងពេលសន្តិភាព និងពេលសង្គ្រាម | កថាខណ្ឌ ១៨-២៤ |
| សេចក្តីសន្និដ្ឋាន | កថាខណ្ឌ ២៤-២៦ |

## ក. លក្ខណៈ និងនិយមន័យអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

១. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាការវាយប្រហារយ៉ាងសាហាវយង់ឃ្នងមកលើសេចក្ដីថ្លៃថ្នូរមនុស្សជាតិ ហេតុនេះប៉ះពាល់ដល់មនុស្សជាតិគ្រប់រូប[1]។ ចំណុចនេះត្រូវបានគូសបញ្ជាក់នៅក្នុងរឿងក្ដី *Weller* ដែលតុលាការកំពូលប្រចាំភូមិភាគចក្រភពអង់គ្លេស បានកំណត់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាការវាយប្រហារមកលើសេចក្ដីថ្លៃថ្នូរមនុស្សជាតិ[2]។ ដោយសារថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាប្រមាថយ៉ាងធ្ងន់ធ្ងរមកលើសេចក្ដីថ្លៃថ្នូរមនុស្សជាតិ ទើប ការវិនិច្ឆ័យទោសចំពោះឧក្រិដ្ឋកម្មនេះ និងជាទូទៅ ការបង្ក្រាបឧក្រិដ្ឋកម្មនេះគឺជាកាតព្វកិច្ចមួយរបស់មនុស្សជាតិទាំងមូល។

២. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានកំណត់និយមន័យជាលើកដំបូងនៅក្នុងធម្មនុញ្ញរបស់សាលាក្ដីយោធាអន្តរជាតិនៅ Nuremberg។ យោងតាមមាត្រា ៦(គ) នៃធម្មនុញ្ញនេះ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវកំណត់និយមន័យថាជា "ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលបានប្រព្រឹត្តមកលើប្រជាជនស៊ីវិលណាក៏ដោយ នៅមុនពេល ឬក្នុងអំឡុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនានៅក្នុងការអនុវត្ត ឬពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មណាដែលស្ថិតនៅក្នុងយុត្តាធិការរបស់សាលាក្ដីនេះ ទោះថាបានរំលោភបំពាន ឬមិនបានរំលោភបំពានច្បាប់ជាតិរបស់ប្រទេសដែលឧក្រិដ្ឋកម្មនោះបានប្រព្រឹត្តឡើងក៏ដោយ"។

៣. ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ ដែលអនុញ្ញាតឲ្យមានការជំនុំជម្រះក្ដីនៅក្នុងភូមិភាគដែលស្ថិតនៅក្រោមការកាន់កាប់[3] មាននិយមន័យស្រដៀងគ្នានេះ ហើយ ធម្មនុញ្ញតូក្យូ ក៏មាននិយមន័យស្រដៀងគ្នានេះដែរ[4]។

---

[1] ICTY រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង* Erdemović រឿងក្ដីលេខ IT-96-22-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៧ កថាខណ្ឌ ២១។

[2] ICTY រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង* Kupreškić *និងអ្នកផ្សេងទៀត* រឿងក្ដីលេខ IT-95-16-T អង្គជំនុំជម្រះសាលាដំបូង II សាលក្រម ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ៥៥៥។

[3] មាត្រា II (១)(គ) ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ លេខ ១០។

[4] មាត្រា ៥(គ)នៃធម្មនុញ្ញសាលាក្ដីយោធាអន្តរជាតិសម្រាប់ចុងបូព៌ា។

៤. ចាប់តាំងពីមានការជំនុំជម្រះក្តីក្រោយសង្គ្រាមលោកលើកទី ២ មក ការហាមឃាត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានក្លាយជាទំនៀមទម្លាប់យ៉ាងច្បាស់ហើយ[5]។

៥. អ.វ.ត.ក មានយុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចខាងក្រោម៖ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាលគឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬ ដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា ណាមួយដូចជា៖ -ការធ្វើមនុស្សឃាត -ការសម្លាប់រង្គាល -ការធ្វើឱ្យទៅជាទាសករ -ការនិរទេស -ការដាក់ក្នុងមន្ទីរឃុំឃាំង -ការធ្វើទារុណកម្ម -ការរំលោភលើផ្លូវភេទ -ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា -អំពើអមនុស្សធម៌ផ្សេងៗទៀត"។

៦. ទោះបីជាមិនមានសន្និសញ្ញាច្បាស់លាស់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិយ៉ាងណាក៏ដោយ ក៏គេច្បាស់ជាអាចទាញយកធាតុផ្សំមួយចំនួននៅក្នុងនិយមន័យដែលមានឫសគល់ពីធម្មនុញ្ញ Nuremberg គឺ ប្រភេទរួមនៃអំពើឧក្រិដ្ឋរាប់តាំងពីអំពើហិង្សា រហូតដល់ការធ្វើទុក្ខបុកម្នេញ ធាតុផ្សំបរិបទនៃការវាយប្រហារមកលើប្រជាជនស៊ីវិល និងធាតុផ្សំគោលនយោបាយ។

៧. គួរកត់សម្គាល់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនតម្រូវឱ្យមានចំណងពាក់ព័ន្ធជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ។ ទោះបីជាថា ធម្មនុញ្ញ Nuremberg បានភ្ជាប់ការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅនឹងជម្លោះប្រដាប់អាវុធអន្តរជាតិយ៉ាងណាក៏ដោយ ក៏ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ មិនតម្រូវឱ្យមានចំណងពាក់ព័ន្ធបែបនោះឡើយ។ ការភ្ជាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅនឹងជម្លោះប្រដាប់អាវុធនៅក្នុងលក្ខន្តិកៈតុលាការ ICTY[6] ចាំបាច់ត្រូវត្រួតពិនិត្យតាមបរិបទ គឺថា តុលាការនេះបានបង្កើតឡើងដើម្បីបង្ការ និងបង្ក្រាបការប្រព្រឹត្តិអំពើឃោរឃៅនៅក្នុងអំឡុងពេលសង្គ្រាមប្រដាប់អាវុធនៅអតីតយូហ្គោស្លាវី។ លក្ខន្តិកៈរបស់ អ.វ.ត.ក តុលាការ ICTR និងតុលាការ ICC មិនតម្រូវឱ្យមានចំណងពាក់ព័ន្ធជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ។

---

[5] បញ្ជាក់ពីគោលការណ៍ច្បាប់អន្តរជាតិដែលទទួលស្គាល់ដោយធម្មនុញ្ញតុលាការ Nürenberg មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ៩៥(I) (ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ១៩៤៦)។ ICTY រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Dusko Tadić* រឿងក្តីលេខ IT-94-1-T អង្គជំនុំជម្រះសាលាដំបូង II សាលក្រម ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៦២៣។

[6] មាត្រា ៥ នៃលក្ខន្តិកៈ ICTY។

ដូច្នេះ គេអាចសន្និសដ្ឋានយ៉ាងសមហេតុផលថា ចំណងពាក់ព័ន្ធបែបនេះមិនមែនជាលក្ខខណ្ឌតម្រូវតាមទំនៀមទម្លាប់ច្បាប់ឡើយ ប៉ុន្តែគ្រាន់តែជាការកម្រិតយុត្តាធិការនៅក្នុងច្បាប់របស់សាលាក្តីមួយចំនួនតែប៉ុណ្ណោះ[7]។

៨. ចុងក្រោយ ចាប់តាំងពីមានការជំនុំជម្រះក្តី Nuremberg មក គេបានទទួលស្គាល់ថា ចារី និងជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចមានសញ្ជាតិដូចគ្នា[8]។

៩. បន្ទាប់ពីសេចក្តីអង្កេតបឋមទាំងនេះ ឥឡូវនេះ ខ្ញុំនឹងពិនិត្យបញ្ហាចោទថាតើ ការវាយប្រហារមកលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធ អាចជាការវាយប្រហារមកលើប្រជាជនស៊ីវិលដែរឬអត់ និងថាតើការវាយប្រហារបែបនោះគឺជាច្បាប់នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែរឬអត់។

១០. ដូចបានកត់សម្គាល់ហើយ និយមន័យតាមទំនៀមទម្លាប់ច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានធាតុផ្សំបរិបទគឺ “ការវាយប្រហារសំដៅលើប្រជាជនស៊ីវិល”។ ធាតុផ្សំបរិបទនេះបែងចែកឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឲ្យខុសពីឧក្រិដ្ឋកម្មធម្មតា[9] ។ ពាក្យថា “ការវាយប្រហារ” សំដៅលើទង្វើដែលគេហាមឃាត់ ឧទាហរណ៍ ការធ្វើមនុស្សឃាត ការរំលោភផ្លូវភេទ ការធ្វើទារុណកម្ម ។ល។ និងការរួមបញ្ចូលគ្នានៃអំពើបែបនេះ។ ការវាយប្រហារ ចង់សំដៅលើ“យុទ្ធនាការ ឬប្រតិបត្តិការ”ប្រឆាំងនឹងប្រជាជនស៊ីវិល[10]។ ពាក្យថា (ប្រជាជនស៊ីវិល)“ណាក៏ដោយ” បង្ហាញថាសមាជិកផ្សេងៗនៃប្រជាជនស៊ីវិលគឺជាគោលដៅ ចំណែកឯពាក្យថា “ប្រជាជន”សំដៅលើជនរង

---

[7] ICTY រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Erdemović* រឿងក្តីលេខ IT-96-22-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៧ កថាខណ្ឌ ២១។ សំណុំរឿងល ០០៣ ឯកសារ D87/2/1.7/1 ដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងនឹងជាមួយនឹងជម្លោះប្រដាប់អាវុធ ថ្ងៃទី០៥ ខែមេសា ឆ្នាំ ២០១៦។

[8] រឿងក្តី J. និង R អាល្លឺម៉ង់ តុលាការកំពូល នៅភូមិភាគកាន់កាប់ដោយចក្រភពអង់គ្លេស សាលដីកា ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៤៨ កថាខណ្ឌ ១៦៧-១៧១។ រឿងក្តី *Enigster* អ៊ីស្រាអែល តុលាការស្រុក តែល អាវីវ សាលក្រម ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៥៥ កថាខណ្ឌ ៤២។ SCSL រឿងក្តី *រដ្ឋអាជ្ញាលតទល់នឹង Issa Hassan Sesay, Morris Kallon និង Augustine Gbao* រឿងក្តីលេខ SCSL-04-15-T សាលក្រម ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ៨៤។

[9] ICTY រឿងក្តី *រដ្ឋអាជ្ញាលតទល់នឹង Dragoljub Kunarac, Radomir Kovac និង Zoran Vukovic,* IT-96-23 & IT-96-23/1-A អង្គជំនុំជម្រះតុលាការកំពូល សាលដីកា ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ៩១។

[10] អង្គបុរេជំនុំជម្រះ II សេចក្តីសម្រេច យោងតាមមាត្រា៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីបទចោទរបស់រដ្ឋអាជ្ញាមកលើ Jean-Pierre Bemba Gombo, ICC-01/05-01/08-424 កថាខណ្ឌ ៧៥។

គ្រោះជាច្រើននាក់តាមន័យគិតពីចំនួន[11]។ ហេតុនេះ ធាតុផ្សំបរិបទនេះ មិនរាប់បញ្ចូលការវាយប្រហារដោយចៃដន្យ ការវាយប្រហារដែលមិនជាប់ពាក់ព័ន្ធ ការវាយប្រហារនៅដាច់ដោយឡែក ការវាយប្រហារតែមួយ ឬដោយឧបទ្ទវហេតុមកលើជនស៊ីវិលឡើយ[12]។ នេះបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាឧក្រិដ្ឋកម្មសមូហភាពចំពោះចារី និងជនរងគ្រោះ។

១១. ហេតុនេះ និយមន័យអំពីពាក្យថា "ជនស៊ីវិល" មានសារៈសំខាន់ណាស់។ ការប្រើប្រាស់ពាក្យថា "ជនស៊ីវិល"នៅក្នុងនិយមន័យអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺស្របគ្នាជាមួយនឹងភាពខុសគ្នារវាងជនស៊ីវិល ជាមួយនឹងយុទ្ធជននៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ហើយដោយសារមូលហេតុនេះ ទើប មូលហេតុនៃភាពខុសគ្នានេះ និងការវិវត្តនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ គួរយកមកពិចារណានៅពេលដែលកំណត់និយមន័យអំពីពាក្យថា"ជនស៊ីវិល"តាមគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

## ខ. និយមន័យអំពីជនស៊ីវិលនៅក្នុងជម្លោះប្រដាប់អាវុធ

១២. គោលការណ៍ស្តីពីភាពខុសគ្នារវាងជនស៊ីវិល ជាមួយនឹងយុទ្ធជន គឺជាគោលការណ៍មួយក្នុងចំណោមគោលការណ៍ចាស់នៃច្បាប់មនុស្សធម៌អន្តរជាតិដែលមានឫសគល់អាចរកឃើញមាននៅក្នុងទ្រឹស្តីសង្គ្រាមដ៏យុត្តិធម៌ ប៉ុន្តែក៏មាននៅក្នុងប្រពៃណី និងសាសនាផ្សេងទៀតដែរ[13]។ គោលការណ៍នេះបានលើកឡើងជាលើកដំបូងនៅក្នុងក្រម Lieber ឆ្នាំ ១៨៦៣[14]។ ការបញ្ជាក់ច្បាស់អំពីគោលការណ៍នេះនៅសម័យទំនើប មានឃើញនៅក្នុងមាត្រា ៥០ នៃពិធីសារបន្ថែម I លើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ដែលការអនុម័តពិធីសារនេះនៅឆ្នាំ ១៩៧៧ មានន័យថាជាច្បាប់ទំនៀមទម្លាប់ហើយ[15]។

---

[11] សេចក្តីសម្រេច យោងតាមមាត្រា ១៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីការអនុញ្ញាតឱ្យស៊ើបសួរលើស្ថានភាពនៅសាធារណរដ្ឋកេនយ៉ា អង្គបុរេជំនុំជម្រះ, ICC-01/09 កថាខណ្ឌ ៧៧។

[12] ICTY រឿងក្តី *Tadić* អង្គជំនុំជម្រះសាលាដំបូង សាលក្រម ខាងលើ កថាខណ្ឌ ៦៤៨។

[13] Michael Walzer *សង្គ្រាមដ៏យុត្តិធម៌ និងអយុត្តិធម៌* បោះពុម្ពលើកទី ២ (ញ៉ូយ៉ក៖ សៀវភៅមូលដ្ឋាន ឆ្នាំ ១៩៩២)។ Terry Narid, ed., *ក្រមសីលធម៌សង្គ្រាម និងសន្តិភាព៖ ទស្សនៈវិស័យសាសនា និងមិនសាសនា* (Princeton: សារព័ត៌មានសាកលវិទ្យាល័យ Princeton ឆ្នាំ ១៩៩៦)។

[14] មាត្រា ២២ នៃក្រម Lieber ឆ្នាំ ១៨៦៣។

[15] Jean-Marie Henckaerts និង Louise Doswald-Beck *ទំនៀមទម្លាប់នៃច្បាប់មនុស្សធម៌អន្តរជាតិ* វ៉ុល I៖ វិធាន (ឆ្នាំ ២០០៥) វិធាន ៥, ICTY រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Tihomir Blaškić,* IT-95-14-A, សាលដីកា អង្គជំនុំជម្រះតុលាការ

១៣. នៅក្នុងបរិបទជម្លោះប្រដាប់អាវុធអន្តរជាតិ ជនស៊ីវិល គឺជាជនដែលមិនមែនជាយុទ្ធជន រួមមានជនដែលបានទម្លាក់អាវុធ ជនដែលបានចាកចេញពីកងទ័ព និងជនដែលបាត់បង់សមត្ថភាពប្រយុទ្ធ[16] ។ ភ្នាក់ងារអនុវត្តច្បាប់ ដូចជា នគរបាលដែលរក្សាសណ្តាប់ធ្នាប់ផ្ទៃក្នុង ត្រូវចាត់ទុកថាជាជនស៊ីវិល តាមគោលបំណងនៃច្បាប់មនុស្សធម៌អន្តរជាតិ ប្រសិនបើគាត់មិនចូលរួមផ្ទាល់នៅក្នុងសកម្មភាពអរិភាព ឬគាត់មិនបានបញ្ចូលនៅក្នុងកងកម្លាំងប្រដាប់អាវុធ[17]។

១៤. នៅក្នុងជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ជនស៊ីវិល គឺជាជនដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ[18]។ និយមន័យអំពីកងកម្លាំងប្រដាប់អាវុធ គឺមានន័យទូទាយគួរសមដោយរាប់បញ្ចូលទាំង "ជនដែលមិនបានបញ្ចូលនៅក្នុងនិយមន័យអំពីកងទ័ពនៅក្នុងច្បាប់ជាតិរបស់ប្រទេសមួយចំនួន (កម្លាំងឃាម គយ នគរបាលជាតិ ឬកងកម្លាំងស្រដៀងគ្នានេះ)"[19]។ បន្ថែមពីលើនេះទៀត ជនដែលមិនរាប់បញ្ចូលជាក្រុមជនស៊ីវិល គឺជាជនដែលចូលរួមផ្ទាល់នៅក្នុងសកម្មភាពអរិភាព ដោយចូលរួមជាបុគ្គល ឬក្នុងនាមជាសមាជិកនៃក្រុមប្រដាប់អាវុធដែលមានការចាត់តាំង។ សមាជិកនៃក្រុមប្រដាប់អាវុធដែលមានការចាត់តាំង នឹងត្រូវចាត់ទុកថាជាជនស៊ីវិល នៅពេលដែលគេលែងចូលរួមផ្ទាល់នៅក្នុងសកម្មភាពអរិភាព ឬនៅពេលដែលគាត់បាត់បង់សមត្ថភាពប្រយុទ្ធ។

---

កំពូល ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ១១០ និង ១១៣-១១៤។ អ.វ.ត.ក សំណុំរឿងលេខ ០០២/០១ *នួន ជា និង ខៀវ សំផន* អង្គជំនុំជម្រះសាលាដំបូង សាលក្រម ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨៥។

[16] ICTY រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Kunarac,* IT-96-23 អង្គជំនុំជម្រះសាលាដំបូង សាលក្រម ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៤២៨។ ICTY រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Jean-Paul Akayesu,* ICTR-96-4-T អង្គជំនុំជម្រះសាលាដំបូង I សាលក្រម ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥៨២។ Henckaerts និង Doswald-Beck ខាងលើ វិធាន ៣, ២៥, ២៧ ដល់ ៣១, ៣៣ ដល់ ៣៤, ៤៧ ដល់ ៤៨, ១១១ និង ១៣៤ ដល់ ១៣៨។

[17] SCSL រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Issa Hassan Sesay, Morris Kallon និង Augustine Gbao,* SCSL-04-15-T សាលក្រម ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ៨៧ និង ៨៨។ ICTY រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Oric,* IT-03-68-T សាលក្រម ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៦ កថាខណ្ឌ ១៨៧-១៨៨ និង ២១៥-២២១។ ICTY រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Tihomir Blaškić,* IT-95-14-T, សាលក្រម ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ៥៥៣-៥៥៦។

[18] មាត្រា ៣ រួមនៃអនុសញ្ញាទីក្រុងហ្សឺណែវ។ មាត្រា ១, ៤ និង ១៣ នៃពិធីសារបន្ថែម II លើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩។ ICTY រឿងក្តី *Blaškić,* អង្គជំនុំជម្រះសាលាដំបូង សាលក្រម ខាងលើ កថាខណ្ឌ ២១៤។

[19] *មតិយោបល់ស្តីពីពិធីសារបន្ថែមចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៧៧ បន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩* ទំព័រ ១៣៥២។

១៥. នៅក្នុងរឿងក្តី Kayishema អង្គជំនុំជម្រះសាលាដំបូង ICTR បានផ្តល់មតិយោបល់ថា "និយមន័យទូលំទូលាយអំពីជនស៊ីវិល អាចអនុវត្តបាន ហើយនៅក្នុងបរិបទស្ថានភាពនៅទីក្រុង Kibuye ដែលមិនមានជម្លោះប្រដាប់អាវុធ និយមន័យបែបនេះរាប់បញ្ចូលជនទាំងអស់ ក្រៅពីជនដែលមានករណីយកិច្ចរក្សាសណ្តាប់ធ្នាប់សាធារណៈ ហើយមានមធ្យោបាយសមស្របតាមច្បាប់ដើម្បីប្រើប្រាស់កម្លាំង។ ឧទាហរណ៍ ជនដែលមិនមែនជាជនស៊ីវិល រាប់បញ្ចូលទាំងសមាជិកនៃ FAR, RPF នគរបាល និងប៉េអឹមជាតិ"[20]។

១៦. ការលើកឡើងនេះចាំបាច់ត្រូវអានយកខ្លឹមសារជាមួយនឹងសេចក្តីបញ្ជាក់ដូចខាងក្រោមនេះ៖ "នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ មានលក្ខខណ្ឌតម្រូវពាក់ព័ន្ធសំខាន់ទាំងអស់ដើម្បីពិចារណាថា ស្ថានភាពនៅរ៉ាវ៉ាន់ដា នៅក្នុងអំឡុងខែ មេសា ខែ ឧសភា ខែ មិថុនា និងខែ កក្កដា ឆ្នាំ ១៩៩៤ គឺជាជម្លោះប្រដាប់អាវុធ មិនមានលក្ខណៈអន្តរជាតិ"[21]។

១៧. ហេតុនេះ និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូង អំពីជនស៊ីវិល គឺពាក់ព័ន្ធនឹងស្ថានភាពជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ហើយក៏មិនពាក់ព័ន្ធនឹងស្ថានភាពដែលគ្មានជម្លោះប្រដាប់អាវុធដែរ។ ប៉ុន្តែ និយមន័យនេះអាចបកស្រាយថាជាការកំណត់និយមន័យទូទៅអំពីជនស៊ីវិល ដោយមិនរាប់បញ្ចូល និងដោយរាប់បញ្ចូលកម្លាំងប្រដាប់អាវុធ អាស្រ័យតាមកាលៈទេសៈ។ ហេតុនេះ កងកម្លាំងនគរបាល ឬយោធា នឹងមិនរាប់បញ្ចូលនៅក្នុងនិយមន័យអំពីជនស៊ីវិលឡើយ នៅពេលដែលពួកគេចូលអន្តរាគមន៍នៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ ឬមិនមែនអន្តរជាតិ។

## គ. បុគ្គលិកយោធាជាជនស៊ីវិលនៅក្នុងអំឡុងពេលសន្តិភាព និងពេលសង្គ្រាម

១៨. មិនមានភាពខុសគ្នារវាងជនស៊ីវិល ជាមួយនឹងយុទ្ធជនឡើយនៅក្នុងអំឡុងពេលសន្តិភាព ប៉ុន្តែជនគ្រប់រូបត្រូវទទួលបានការការពារដូចគ្នាតាមច្បាប់។ សមាជិកនៃកងកម្លាំងប្រដាប់អាវុធនៅក្នុងអំឡុងពេលសន្តិភាព មិនមានឯកសិទ្ធិបន្ថែមឡើយ ហើយត្រូវអនុវត្តតាមច្បាប់ព្រហ្មទណ្ឌ ដូចពលរដ្ឋផ្សេងទៀតដែរ ទោះបីជាគេអាចជាប់យុត្តាធិការបម្រើយោធាក៏ដោយ។ សេចក្តីថ្លែងការណ៍ជាគំរូស្តីពីតួនាទីរបស់ទាហាននៅក្នុងច្បាប់អង់គ្លេស ត្រូវបានធ្វើឡើងដោយលោក James

---

[20] ICTR រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Kayishema,* ICTR-95-1 អង្គជំនុំជម្រះសាលាដំបូង សាលក្រម ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១២៧។

[21] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១៧២។

Mansfield ប្រធានតុលាការកំពូល។ គាត់បាននិយាយសំដៅលើករណីយកិច្ចរបស់ទាហានដែលត្រូវបំពេញតួនាទីជាពលរដ្ឋក្នុងការបង្ក្រាបការរំលោភបំពានសន្តិភាព។ នៅឆ្នាំ ១៨០២ គាត់មានប្រសាសន៍ថា "ចាប់តាំងពីមានការនិយាយយ៉ាងច្រើនអំពីទាហាន ខ្ញុំនឹងកែតម្រូវសញ្ញាណយល់ខុសមួយដ៏ចម្លែកដែលធ្លាយដល់បរទេស សញ្ញាណដែលថា ដោយសារថាឋានៈជាទាហាន គេលែងជាពលរដ្ឋទៀតហើយ។ ទាហាន មានសិទ្ធិទាំងអស់ដូចពលរដ្ឋផ្សេងទៀតដែរ..."។ ដោយពិភាក្សាពីករណីយកិច្ចរបស់ទាហានក្នុងការបង្ការឧក្រិដ្ឋកម្ម គាត់មានប្រសាសន៍បន្ថែមថា "ហេតុនេះ សំខាន់ណាស់គឺថា កំហុសនេះគួរតែកែតម្រូវ កំហុសដែលសន្មតថា ដោយសារថាមានលក្ខណៈបន្ថែមជាទាហាន ជនជាតិអង់គ្លេស ផ្អាកមានសិទ្ធិ ឬករណីយកិច្ចជាជនជាតិអង់គ្លេស"[22]។

១៩. ភាពមិនខុសគ្នារវាងក្រុមប្រជាជនផ្សេងៗគ្នានៅក្នុងអំឡុងពេលសន្តិភាព អាចពន្យល់បានតាមរយៈអង្គហេតុដែលថា គោលការណ៍ស្តីពីភាពខុសគ្នានៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ បានអនុវត្តដើម្បីការពារ និងកាត់បន្ថយការឈឺចាប់របស់ប្រជាជននៅក្នុងប្រតិបត្តិការយោធា នៅពេលដែលមិនមានការការពារផ្លូវច្បាប់ជាធម្មតា។ នៅក្នុងអំឡុងពេលសន្តិភាព ភាពបន្ទាន់ផ្នែកសីលធម៌ ក្រមសីលធម៌ការអនុវត្ត និងផ្នែកច្បាប់ដែលជាមូលដ្ឋាននៃគោលការណ៍ស្តីពីភាពខុសគ្នា មិនយកមកអនុវត្តឡើយ។

២០. ដូចបានកត់សម្គាល់ខាងលើផងដែរ ការហាមឃាត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺដើម្បីការពារសេចក្តីថ្លៃថ្នូរមនុស្សជាតិ។ ការហាមឃាត់នេះគឺដើម្បីការពារមនុស្សពីការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។ គោលបំណងដែលធ្វើឲ្យអំពើបែបនេះជាបទឧក្រិដ្ឋចាប់តាំងពីមានធម្មនុញ្ញ Nuremberg មក គឺដើម្បីឲ្យមានការវិនិច្ឆ័យទោសចំពោះឧក្រិដ្ឋកម្មដែលរដ្ឋ ឬអង្គការប្រព្រឹត្តមកលើពលរដ្ឋខ្លួនឯង ឬប្រព្រឹត្តជាទូទៅមកលើប្រជាជននៅក្នុងស្ថានភាពជម្លោះប្រដាប់អាវុធ និងនៅក្នុងអំឡុងពេលសន្តិភាពផងដែរ។ នេះដោយសារថា វិធានការការពារពីច្បាប់មនុស្សធម៌ មិនអនុវត្តឡើយនៅក្នុងអំឡុងពេលសន្តិភាព ហើយដោយសារថា នៅពេលដែលច្បាប់បែបនេះអនុវត្តនៅក្នុងស្ថានភាពជម្លោះប្រដាប់អាវុធ ច្បាប់នេះអនុវត្តតែចំពោះទាហានសត្រូវ ឬជនស៊ីវិលសត្រូវតែប៉ុណ្ណោះ ហេតុនេះហើយធ្វើឲ្យប្រជាជនដែលរដ្ឋរបស់ខ្លួនវាយប្រហារមកលើពួកគាត់នោះ មិនត្រូវបានការពារឡើយ។

[22] Clode កងកម្លាំងយោធា,i, ១៤៤;ii, ១៤៣ នៅក្នុងសៀវភៅណែនាំស្តីពីច្បាប់យោធា (ការិយាល័យសង្គ្រាម ឆ្នាំ ១៨៩៤) ទំព័រ ២៨៦។

២១. ដូច្នេះ មានការអះអាងថា នៅក្នុងអំឡុងពេលសន្តិភាព សមាជិកនៃកងកម្លាំងប្រដាប់អាវុធ គឺជាផ្នែកមួយនៃប្រជាជនស៊ីវិលដែលអាចក្លាយជាគោលដៅនៃការវាយប្រហារ។

២២. ប្រសិនបើអះអាងផ្ទុយពីនេះ នោះនឹងនាំឲ្យមានស្ថានភាពមិនសមហេតុផល គឺថា ការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធមកលើបុគ្គលិកយោធានៅក្នុងអំឡុងពេលសន្តិភាព មិនបង្កើតឲ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ប៉ុន្តែការវាយប្រហារស្រដៀងគ្នានេះមកលើប្រជាជនក្រុមផ្សេងទៀតបែរជាបង្កើតឲ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅវិញ។

២៣. ទោះជាក្នុងបរិបទជម្លោះប្រដាប់អាវុធក៏ដោយ ក៏សមាជិកកងទ័ពអាចជាផ្នែកមួយនៃប្រជាជនស៊ីវិលដែលគេវាយប្រហារដែរ។ ទី១ ដូចបានកត់សម្គាល់ខាងលើដែរ ភាពខុសគ្នារវាងជនស៊ីវិលជាមួយនឹងយុទ្ធជន យកមកអនុវត្តតែចំពោះប្រជាជន"សត្រូវ" មិនមែនប្រជាជនផ្ទាល់ខ្លួនរបស់រដ្ឋដែលវាយប្រហារនោះឡើយ។ ប្រសិនបើរដ្ឋវាយប្រហារសមាជិកកងទ័ពខ្លួនឯង អំពើនេះគឺត្រូវតាមធាតុផ្សំបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទី ២ ប្រជាជនដែលជាគោលដៅនៃការវាយប្រហារ គួរតែ"ភាគច្រើន"ជាជនស៊ីវិល។ ហេតុនេះ លក្ខណៈជាជនស៊ីវិលមិនផ្លាស់ប្តូរដោយសារវត្តមានរបស់យោធានៅក្នុងចំណោមប្រជាជនទាំងនោះឡើយ[23]។ ធាតុផ្សំដ៏សំខាន់គឺថា តើការវាយប្រហារនេះសំដៅលើជនស៊ីវិល ដែរឬអត់។

២៤. បន្ថែមពីលើនេះទៀត ប្រសិនបើមានធាតុផ្សំបរិបទនៃការវាយប្រហារមកលើប្រជាជនស៊ីវិល នោះជនរងគ្រោះនៃឧក្រិដ្ឋកម្មនេះអាចជាបុគ្គលិកយោធា ដោយមិនគិតថាតើពួកគាត់ត្រូវតាមនិយមន័យអំពីយុទ្ធជន តាមច្បាប់មនុស្សធម៌អន្តរជាតិដែរឬអត់នោះឡើយ ដរាបណាមានចំណងពាក់ព័ន្ធរវាងការវាយប្រហារនោះ ជាមួយនឹងបរិបទនៃការវាយប្រហារមកលើប្រជាជនស៊ីវិល។ នេះគឺជាការទាញសេចក្តីសន្និដ្ឋានយ៉ាងសមហេតុផលពីអង្គហេតុដែលថា បរិបទនៃការវាយប្រហារនោះគួរសំដៅលើប្រជាជនស៊ីវិល។ រឿងក្តីមួយចំនួនផ្អែកលើច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ គាំទ្រការយល់ឃើញដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចប្រព្រឹត្តឡើងមកលើទាហាន[24]។ នៅក្នុង

---

[23] ICTY រឿងក្តី *Tadić* សាលក្រម ខាងលើ កថាខណ្ឌ ៦៣៨-៦៤៣។ ICTY រឿងក្តី *Blaškić* សាលដីកា ខាងលើ កថាខណ្ឌ ១១៣ និង ១១៥។

[24] តុលាការកំពូលអាល្លឺម៉ង់នៅភូមិភាគកាន់កាប់ដោយចក្រភពអង់គ្លេស សាលដីកា រឿងក្តីលេខ St S 111/48 ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៤៨ 1 ENTSCHEIDGUNGEN DES OBERSTEN GERICHTSHOFES DER BRITISCHEN ZONE IN STRAFSACHEN ទំព័រ ២១៩ និង ២២៨ (ឆ្នាំ ១៩៤៨)។ តុលាការកំពូលអាល្លឺម៉ង់នៅភូមិភាគកាន់កាប់ដោយចក្រភព

រឿងក្តី Mršksić ផងដែរ អង្គហេតុគឺថា ឈ្លើយសឹក គឺជាគោលដៅនៃការវាយប្រហារ ដោយសារពួកគាត់ជាសមាជិកនៃកងទ័ពសត្រូវ ដែលនេះផ្តាច់ទំនាក់ទំនងការវាយប្រហារនេះពីបរិបទនៃការវាយប្រហារមកលើប្រជាជនស៊ីវិល ហើយដកការវាយប្រហារនេះចេញពីប្រភេទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[25]។ ប្រសិនបើការវាយប្រហារមកលើឈ្លើយសឹកបានប្រព្រឹត្តឡើងដោយមូលហេតុដូចគ្នានឹង បរិបទនៃការវាយប្រហារមកលើជនស៊ីវិលនោះ អង្គហេតុដែលថា ឈ្លើយសឹកនោះជាទាហាន នឹងមិនកែប្រែឋានៈឧក្រិដ្ឋកម្មនោះជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។

## ឃ. សេចក្តីសន្និដ្ឋាន

២៥. ជាសេចក្តីសន្និដ្ឋាន ការវាយប្រហារមកលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលប្រព្រឹត្តឡើងដោយរដ្ឋ ឬអង្គការរបស់ពួកគាត់ខ្លួនឯង អាចត្រូវតាមធាតុផ្សំបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងអំឡុងពេលសន្តិភាព។ នៅក្នុងបរិបទជម្លោះប្រដាប់អាវុធ និយមន័យអំពីជនស៊ីវិលទោះជាក្នុងន័យទូលាយក៏ដោយ ក៏នឹងមិនរាប់បញ្ចូលសមាជិកនៃកងទ័ពជាយុទ្ធជន ឬសមាជិកប្រជាជនដែលចូលរួមសកម្មភាពអរិភាពឡើយ។ ប៉ុន្តែ និយមន័យនេះនឹងរាប់បញ្ចូលប្រជាជនរបស់រដ្ឋដែលវាយប្រហារ ឬប្រជាជនរបស់រដ្ឋសត្រូវដែលមិនចូលរួមសកម្មភាពអរិភាព។

២៦. ការកំណត់ថាតើការវាយប្រហារសំដៅលើប្រជាជនស៊ីវិល ឬអត់នោះ គួរតែធ្វើឡើងតាមករណីនីមួយៗ ដោយពិនិត្យមើលកាលៈទេសៈជុំវិញទាំងអស់។ គួរពិចារណាផងដែរលើគុណតម្លៃដែលត្រូវការពារ និងស្មារតីច្បាប់ដែលត្រូវការពារសេចក្តីថ្លៃថ្នូរមនុស្សជាតិ។

*[ហត្ថលេខា]*

សាស្ត្រាចារ្យ Nicholas Tsagourias

---

អង់គ្លេស សាលដីកា រឿងក្តីលេខ St S 309/49 ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៤៩ 2 ENTSCHEIDGUNGEN DES OBERSTEN GERICHTSHOFES DER BRITISCHEN ZONE IN STRAFSACHEN ទំព័រ ២៣១ (ឆ្នាំ ១៩៤៨)។

[25] ICTY រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Mile Mršksić និង Veselin Šljivancanin,* IT-95-13/1-A អង្គជំនុំជម្រះតុលាការកំពូល សាលដីកា ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៩ កថាខណ្ឌ ៣៥-៤៥។